ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៣ លេខ ១៣ | សប្តាហ៍ទី ៣ ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០១៣

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

p

មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២១.០១.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៨៤ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ១១ រូប ១៤៤៥

២១.០១.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៨៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ៧៦ រូប ១៤៤៦

២១.០១.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៨៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ៧៦ រូប ១៤៤៨

២៣.០១.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩០ ស្តីពី ការដាក់មន្ត្រីរាជការឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងព័ត៌មាន ចំនួន ០១ រូប ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ១៤៥០

២៣.០១.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩១ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ១៣ រូប ១៤៥១

២៣.០១.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩២ ស្តីពី ការផ្តល់ឋានៈសាស្ត្រាចារ្យ ១៤៥៣

២៣.០១.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩៣ ស្តីពី ការកាត់ផ្ទៃដីទំហំ ៣.៦៨០ ហិកតា ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០០៣ ១៤៦២

២៤.០១.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩៤ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក ជូនឯកឧត្តមឧត្តមសេនីយ៍ទោ សួខ មុនី នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៤៦៣

២៤.០១.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩៥ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយឯក អេង ម៉ាន់នី នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៤៦៤

២៤.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩៦ ស្ដីពី ការតែងតាំងមុខតំណែង លោក ឧត្តមសេនីយ៍ទោ ជុំ សូយ៉ាត ជាទីប្រឹក្សាក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារ ស្រាវជ្រាវជីករុករកអដ្ឋិធាតុជនជាតិបរទេសបាត់ខ្លួននៅកម្ពុជា ឋានៈស្មើ អនុរដ្ឋលេខាធិការ និង ដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក លោក ឧត្តមសេនីយ៍ទោ ជុំ សូយ៉ាត នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ កម្ពុជា នៃក្រសួងមហាផ្ទៃ ១៤៦៥

II. ព្រឹទ្ធសភា

០៥.០២.២០១៣ - សេចក្ដីសំរេចលេខ ០១៣/០២១៣/ពស/សរ ស្ដីពី ការចាត់តាំងក្រុមសមាជិកាព្រឹទ្ធសភា ១៤៦៦

០៥.០២.២០១៣ - សេចក្ដីសំរេចលេខ ០១៤/០២១៣/ពស/សរ ស្ដីពី ការចាត់តាំងអ្នកនាំពាក្យរបស់ព្រឹទ្ធសភា ១៤៦៨

០៨.០២.២០១៣ - សេចក្ដីសំរេចលេខ ០១៦/០២១៣/ពស/សរ ស្ដីពី ការចាត់តាំងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ ១៤៦៩

០៨.០២.២០១៣ - សេចក្ដីសំរេចលេខ ០១៧/០២១៣/ពស/សរ ស្ដីពី ការទទួលស្គាល់ឯកឧត្តម ជុំ ចន ជាសមាជិកព្រឹទ្ធសភាមណ្ឌលភូមិភាគទី ៧ (ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និង ខេត្តព្រះសីហនុ) ជំនួស ឯកឧត្តម អ៊ុំ សារិទ្ធ ដែលបានសុំលាលែង ១៤៧២

III. រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៩.០១.២០១៣ - អនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្ដីពី ការកាត់ដីទំហំសរុប ៩១១.៤៨ ហិកតា នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ក្នុងនោះកាត់ចេញពីដែនជម្រកសត្វព្រៃគូលេន-ព្រហ្មទេព កាត់ចេញពីរមណីយដ្ឋានប្រាសាទព្រះវិហារ កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង ធ្វើប្រទានកម្ម ជំនួសដីសម្បទានសង្គមកិច្ច (វរៈសេនាតូចលេខ ៨១៣) សម្រាប់ប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋសរុប ៥១៣ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ១៤៧៣

២៩.០១.២០១៣ - អនុក្រឹត្យលេខ ៤៥ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៣៦១.៥៨ ហិកតា នៅស្រុករមាសហែក ខេត្តស្វាយរៀង ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង ធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២១៥ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៤៧៧

២៩.០១.២០១៣ - អនុក្រឹត្យលេខ ៤៦ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៥៥១,៣៥ ហិកតា នៅស្រុកវមាសហែក ខេត្តស្វាយរៀង ចេញពីតម្របព្រៃឈើឆ្នាំ ២០០២ និង ធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៩២ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៤៨០

២៩.០១.២០១៣ - អនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ២៥៣,៤២ ហិកតា នៅស្រុករមាសហែក ខេត្តស្វាយរៀង ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង ធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១១៩ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៤៨៣

៣១.០១.២០១៣ - អនុក្រឹត្យលេខ ៤៨ អនក្រ.បក ស្ដីពី បែបបទ និង លក្ខខណ្ឌ នៃការគ្រប់គ្រងអាស៊ីដខ្លាំង ១៤៨៦

២១.១១.២០១២ - អនុក្រឹត្យលេខ **២៥៦៨** ដល់អនុក្រឹត្យលេខ **២៦០០** អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ១៤៩២

IV_ការងារបណ្ដាក្រសួង

១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

២៨.១២.២០១២ - ប្រកាសរួមលេខ ១០០៧ សហវ.ប្រក ស្ដីពី ការផ្ដល់សេវាសាធារណៈរបស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ១៥២៥

២៨.១២.២០១២ - ប្រកាសរួមលេខ ១០០៨ សហវ.ប្រក ស្ដីពី ការផ្ដល់រង្វាន់លើកទឹកចិត្តជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១៥២៩

២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៩.០១.២០១៣ - ប្រកាសលេខ ០០៩ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច បង្កើតរោងចក្រ ផលិតឧបករណ៍ស្ដាប់សម្លេងភ្ជាប់ត្រចៀក, ឧបករណ៍សំរាប់បញ្ចូលថាមពលទូរសព្ទ និង គ្រឿងបន្លាស់អេឡិចត្រូនិច ១៥៣៣

០៩.០១.២០១៣ - ប្រកាសលេខ ០១០ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន បេស ហ៊ែងអឺ (ខេមបូឌា) បង្កើតរោងចក្រ ផលិតទំពក់ព្យួរសម្លៀកបំពាក់ ១៥៣៧

០៩.០១.២០១៣ - ប្រកាសលេខ ០១១ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វីនម៉ាក ស៊ូមេនូហ្វេកឆើរីង បង្កើតរោងចក្រ ផលិតស្បែកជើង ១៥៤១

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៩៨០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រ្គេន ថ្មី អេនធើប្រាយ** ១៥៤៥

១៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៩៩១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេង លាង មិត្ត កសិករ
អ៊ីមផត អិចផត** ១៥៤៧

១៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៩៩២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ីលីង ឡូជីស្ទិក** ១៥៤៩

១៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៩៩៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខិសាល ថេឡឹន មេនេចមេន** ១៥៥១

១៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៩៩៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច.ខេ.ធី ស្ពេសល
អ៊ីឃើណមិក ហ្សូន** ១៥៥៣

១៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៥០០១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡឺ គ្រេហ្ស៊ឺរ ឌុយ ឆៃវ៉ា** ១៥៥៥

១៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៥០០២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វីច រ៉ាប់ប៊ើរ អាគ្រោ
គីធីអ៊ូ អិលធីឌី** ១៥៥៧

២២-៨-២០១១ -លិខិតបញ្ជាក់លេខ ៥០០៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊័រធៀស វីសេសស៍
(ខេមបូឌា) ខូ លីមីធីត** ១៥៥៩

២២-៨-២០១១ -លិខិតបញ្ជាក់លេខ ៥០០៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សហផល ត្រេឌីង** ១៥៦១

២២-៨-២០១១ -លិខិតបញ្ជាក់លេខ ៥០០៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេអឹមខេ ស្តាហ្វ អាសូស៊ី
អេសិន (អេអឹមខេ-អេសអេ) អិលធីឌី** ១៥៦៣

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្ននខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ឯក	**ខួន ស្រេង**	អត្តលេខ	០៣៧៨៨
២- លោកវរសេនីយ៍ឯក	**ខ៊ែត ណាន**	អត្តលេខ	០៥៨៨១
៣- លោកវរសេនីយ៍ឯក	**ប្រាក់ គុណា**	អត្តលេខ	៥៥១៥៩
៤- លោកវរសេនីយ៍ឯក	**ម៉ិះ ម៉ាន់**	អត្តលេខ	០៥៤១៣
៥- លោកវរសេនីយ៍ឯក	**រស់ សារឹម**	អត្តលេខ	០៧៥៥៩
៦- លោកវរសេនីយ៍ឯក	**ពេជ្រ យ៉ុន**	អត្តលេខ	០១៣១៥
៧- លោកវរសេនីយ៍ឯក	**ព្រាប ឧទ្ធិ**	អត្តលេខ	០៦៥២៦
៨- លោកវរសេនីយ៍ឯក	**គុម នេត**	អត្តលេខ	៦៧៦៩៨
៩- លោកស្រីវរសេនីយ៍ឯក	**សេត ណារី**	អត្តលេខ	០២២៦៤
១០- លោកវរសេនីយ៍ឯក	**គាប់ លន**	អត្តលេខ	៦៤២៨៤
១១- លោកវរសេនីយ៍ឯក	**ហូរ សាឌី**	អត្តលេខ	០១០២៩

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១១.១៣០១.០៧៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ដើម្បីឡាយព្រះហស្តលេខា
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៣
នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល
ហត្ថលេខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៣

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/០៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ៧៦ រូប ដែលមានគុណបំណាច់

ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោក ចាន់ តារ៉ា
២-លោក អ៊ុង សុផល
៣-លោក តាង សីហា
៤-លោក ឡឿង សុផល
៥-លោក ប៉ែន ស៊ិនសារីណារ័ត្ន
៦-លោក ស៊ឹម បូរ៉ាម៉ី
៧-លោក ខៀវ សាម៉េត
៨-លោក សែម សុតា
៩-លោក យី សុខុម
១០-លោក ឡា ជីយាង
១១-លោក ម៉ី សុម៉ាច
១២-លោក គួច ចាន់ប៊ុនលី
១៣-លោក ឈួ សារ៉ាវុធ
១៤-លោក អ៊ួច បូរ៉ារិទ្ធ
១៥-លោក តាន់ ពៅពិសេរ
១៦-លោក លាង លីណា
១៧-លោក សៀង គង់
១៨-លោក ឡុង ទិចិត្រា
១៩- លោក អៀង ម៉ាន់នី
២០- លោក តាយ សុណា

ខ/គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោក អ៊ុង លីសៀង
២- លោក គ្រួយ លីមហេង

គ/គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោកស្រី ជួន នួននិមល
២-លោក ប៉ែន ច័ន្ទកុមារ

ឃ/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-ឯកឧត្តម អ៊ុត ថុន
២-ឯកឧត្តម មិន ម៉ារ៉ា
១០-លោក វុត សុខា
១១-លោក ពិន ចណ្ណារ៉ូ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

៣-ឯកឧត្តម ស្រួច សុផាន់ណា
៤-លោក យ៉ាន សំបូរ
៥-លោក ប្រាក់ ដុល្លីន
៦-លោក ព្រហ្ម សំអ៊ាន
៧-លោក សិត ខន
៨-លោក មាស ច័ន្ទពិសិដ្ឋ
៩-លោក គិន ច័ន្ទថុល
១២-លោក ហ៊ឹង ប៉ូរ៉ា
១៣-លោកស្រី ឃ្មិន វ៉ាណា
១៤-លោក តាត ប៊ុនថាន
១៥-លោក សុខ គេង
១៦-លោក សុត រ៉ាធី
១៧-លោក អ៊ឹង គីមអៀង

ង/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-លោក ដួង សុខា
២-លោក សឿន សុភក្ត្រា
៣-លោក នូ ផល
៤-លោក ផល ចណ្ណា
៥-លោក ទៀង នី
៦-លោក អ៊ូច សៅធឿន
៧-លោក ពូជ សុផល
៨-លោក សុខ ឡាក់
៩-លោក ដួង សំអួន
១០-លោក ហ៊ុន ឈុនហៀង
១១-លោក ទី សុភ្គបុត្រ
១២-លោក ជា សារឿន
១៣-លោក ទឹង កុមារ
១៤-លោក ស្រួយ ប៉ែន
១៥-លោក ចាប ឧត្តម
១៦-លោក ប៊ូច ពិសី
១៧-លោក ស្វាយ សេងលី
១៨-លោក អ៉ែត បូរក្ស័
១៩-លោក សុខ ជា
២០-លោក សុម លី
២១-លោក សេង ម៉េងឡុង
២២-លោក ឆាយ ចៅគនា

ច/គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ឯកឧត្តម ចាន់ កុលបុត្រ

ឆ/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់សេនា :

១-លោក អ៊ុត សោភ័ណ្ឌារ៉ា
២-លោក មាស ច័ន្ទរិទ្ធ
៣-លោក ជូ សៀងគុង
៤-លោក ហួ សំបូរ
៥-លោក ប៊ុន យ៉ាណូ
៦-លោក ម៉ុង ធីរិទ្ធ

ជ/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១-លោកស្រី សុខ លាស
២-លោក ញ៉ឹង ចាន់ធី
៣-លោក សោម ធីសែម
៤-លោក លី ភុគយាង
៥-លោក គីម ស្រីធន
៦-លោក គិត ខេមរារិទ្ធ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពាទ.១៣០១.០៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣

លេខ ១៤៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/០៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ៧៦ រូប ដែលមានគុណបំណាច់

ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម នួន ញ៉ិត	៨-ព្រះចៅអធិការ សូ សុខា
២-ឯកឧត្តម គីម ចាន់នី	៩-លោក ទូច ចាសនា
៣-ឯកឧត្តម អ៊ុត ហៃសីឡា	១០-លោក នួន ភារិទ្ធិ
៤-ឯកឧត្តម ស៊ា ស៊ីម	១១-លោក គង់ ជូរ៉េន
៥-ឯកឧត្តម សេង ចណ្ណៈ	១២-លោក តាំង សុខហោ
៦-លោកជំទាវ ឆាយ ម៉ិច	១៣-លោក ចាន់ សារិន
៧-លោក អ៊ុំ ស៊ីប៉ាន់ណូ	១៤-លោក ស៊ឹម សិទ្ធិស័ក

ខ/គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោក ម៉ែន ច័ន្ទសុខមេមរិទ្ធ	២- លោក អ៊ាង ភារៈ

គ/គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោក ម៉ឺន វ៉ៃ	៣-លោក នី ស៊ីវុត្ថា
២-លោក ឡៅ ប៊ុនម៉េង	៤-ឯកឧត្តម ឆាយ វិចិត្រ

ឃ/គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន
ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោកជំទាវឧកញ៉ា ជាសុផា គន្ធី	៣-លោក សម ធួន
២-លោកស្រី នួច សៀមយី	៤-លោក អ៊ុំ ករុណា

ង/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-ឯកឧត្តម សេង ហួត	៨-លោក សាយ សុផល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

២- លោក ឆេព សុភាព
៣-លោក គួត សុវណ្ណ
៤-លោក គង់ សុវណ្ណ
៥-លោក យឹម រ៉ាឌី
៦-លោក អ៊ុន សុភ័ស្ត
៧-លោក ឃួន ណារ៉ាន់
៩-លោក រស់ យ៉ារ៉ាណូ
១០-លោក ខឡូ ហ្វុកលី
១១-លោក ខឡូ ណារ៉ាវុធ
១២-លោក សំ ចណ្ណា
១៣-លោក សាត ច័ន្ទដារ៉ារិទ្ធិ
១៤-លោក ចេង ឡេង

ច/គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-ឯកឧត្តម ផូង ទុត្ថា

ឆ/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-លោក យ៉េន ភារិទ្ធ
២-លោក ម៉ី សនសុធា
៣-លោក ច្រឹម ថាវុធ
៤-លោក អ៊ុំ ច័ន្ទមុន្នី
៥-លោក ឃួយ បញ្ញា
៦-លោក ឯម សារួន
៧-លោក ប៉ិច សុម៉ុត
៨-លោក អ៊ូ សុផល
៩-លោក ឈឹម មន
១០-លោក ឃីម សំភា
១១-លោក សួង ពូយ
១២-លោក ឈឹម ចិសាល
១៣-លោក ទី សុភ្ក្តបុត្រ
១៤-លោក ឈឹម សៅរ៉ាន់
១៥-លោក ភោគ ទិបុល
១៦-លោក វៀម រិទ្ធ
១៧-លោក ចណ្ណី ចាសនា
១៨-លោក ស្រេង ម្ញ
១០-លោក ហេង សំបូរ
២០-លោក ស៊ិ ឡៀម
២១-លោក ស៊ិន ចណ្ណដេត
២២-លោក អ៊ុច អ៊ុត
២៣-លោក លឹម ហុកលី
២៤-លោក ហ៊ិន សេដ្ឋា
២៥-លោក តាន់ ឃុនចណ្ណារ៉ា
២៦-លោក សៀង សុខ

ជ/គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ឯកឧត្តម សៀង ស៊ែ
២-សុរក្ខិតោ ណាង សុខធួច

ឈ/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១-លោក ប៉ែន ចំរើន
២-លោក ម៉ាន់ សាខន
៣-លោក តែន សំអន
៤-លោក ឃុត ឌី
៥-លោក ប្រាជ្ញ ម៉ាលីស
៦-លោក ជា ម៉េត

ញ/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១-លោក ម៉ិច ប៉ាល់
២-លោកស្រី ឡេង នូយ
៣-លោកស្រី ដួង សុគន្ធា
៤-លោក លី ហុង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ព្រក.១៣០១.០៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣

លេខ ១២៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
... សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដាក់មន្ត្រីរាជការឋានន្តរសក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងព័ត៌មាន ចំនួន ០១ រូប ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ

ល.រ	គោត្តនាម និង នាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	មុខតំណែង	ឋានន្តរសក្តិ និង ថ្នាក់	ថ្ងៃខែឆ្នាំ ចូលនិវត្តន៍
១	ម៉ាន់ សេងលី	ប	១០-០២-១៩៤៣	អតីតអគ្គនាយក	ឧត្តមមន្ត្រី ថ្នាក់លេខ ១	០១-០៣-២០០៣

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៦៧.១៣០១.០៩១

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៣

[illegible] ច.ល
[illegible]ចែក
[illegible] ខែមករា ឆ្នាំ២០១៣
[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/០៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៣៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ឯក **ហៀក ឫទ្ធី** អត្តលេខ ០២១៣៨
២- លោកវរសេនីយ៍ឯក **ខា សំបូរណ៍** អត្តលេខ ០៦៧៤៩
៣- លោកវរសេនីយ៍ឯក **ហ៊ុល សម្បត្តិ** អត្តលេខ ០៤៥៩១
៤- លោកវរសេនីយ៍ឯក **ឈុក ឈន** អត្តលេខ ០៣៦២៥
៥- លោកវរសេនីយ៍ឯក **សាយ សោភ័ណ្ឌ** អត្តលេខ ០១២៦៨
៦- លោកវរសេនីយ៍ឯក **ឌុក ជិ** អត្តលេខ ៥៤៨៦៤
៧- លោកវរសេនីយ៍ឯក **ពុទ្ធ សន** អត្តលេខ ០៥៩៦
៨- លោកវរសេនីយ៍ឯក **ធីម ឈុនស៊ីម** អត្តលេខ ០២៨៦
៩- លោកវរសេនីយ៍ឯក **ទ៉ាន់ សារិទ្ធ** អត្តលេខ ០២១៩២

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

១០- លោកវរសេនីយ៍ឯក **កែវ សុវណ្ណ** អត្តលេខ ០៦៧៨៩

១១- លោកវរសេនីយ៍ឯក **លូ រ៉ាម៉ូ** អត្តលេខ ៥៦០២៦

១២- លោកវរសេនីយ៍ឯក **រស់ គង់** អត្តលេខ ០១២៧៥

១៣- លោកវរសេនីយ៍ឯក **នួន យ៉ាន** អត្តលេខ ០៤១១ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចាកត. ១៣០១.០៩៤

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៣

លេខៈ ១២១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៣

អគ្គលេខាធិការរងនៃទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/០៩២

ស្តីពី
ការផ្តល់ឋានៈសាស្ត្រាចារ្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា/ៗ

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៩ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣

ត្រាស់បង្គាប់

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ព្រះរាជក្រឹត្យនេះមានគោលបំណងលើកកម្ពស់គុណវុឌ្ឍិរបស់គ្រូបង្រៀន ដើម្បីរួមចំណែកអភិវឌ្ឍការបណ្តុះបណ្តាលធនធានមនុស្សនៅតាមគ្រឹះស្ថានឧត្តមសិក្សាឱ្យមានគុណភាពខ្ពស់។

មាត្រា ២.-

ព្រះរាជក្រឹត្យនេះមានគោលដៅដូចខាងក្រោម៖

- រៀបចំនីតិវិធីនិងយន្តការសម្រាប់ការប្រឡងជ្រើសរើសសាស្ត្រាចារ្យនិងផ្តល់ឋានៈជាសាស្ត្រាចារ្យ
- កំណត់លក្ខខណ្ឌរបស់បេក្ខជនដែលអាចប្រឡងជ្រើសរើសជាសាស្ត្រាចារ្យ។

មាត្រា ៣.-

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រូបង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលមានបំណងទទួលឋានៈជាសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ/សាស្ត្រាចារ្យមហាបរិញ្ញាក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៤.-

វាក្យសព្ទដែលប្រើនៅក្នុងព្រះរាជក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **សាស្ត្រាចារ្យ/សាស្ត្រាចារ្យមហាបរិញ្ញា** សំដៅដល់ឋានៈខ្ពស់បំផុតរបស់គ្រូបង្រៀននៅគ្រឹះស្ថានឧត្តមសិក្សា ដែលមានស្នាដៃបង្រៀននិងស្រាវជ្រាវនៅក្នុងវិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រ និង/ឬបច្ចេកវិទ្យា។
- **សាស្ត្រាចារ្យរង** សំដៅដល់ឋានៈខ្ពស់បន្ទាប់ពីសាស្ត្រាចារ្យ/សាស្ត្រាចារ្យមហាបរិញ្ញារបស់គ្រូបង្រៀននៅគ្រឹះស្ថានឧត្តមសិក្សា ដែលមានស្នាដៃបង្រៀននិងស្រាវជ្រាវនៅក្នុងវិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រ និង/ឬបច្ចេកវិទ្យា។/

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

- **សាស្ត្រាចារ្យជំនួយ** សំដៅដល់ឋានៈខ្ពស់បន្ទាប់ពីសាស្ត្រាចារ្យរងរបស់គ្រូបង្រៀន នៅគ្រឹះស្ថានឧត្តមសិក្សា ដែលមានស្នាដៃបង្រៀននិងស្រាវជ្រាវនៅក្នុងវិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រ និង/ឬបច្ចេកវិទ្យា។
- ចំពោះវិស័យសុខាភិបាល វាក្យសព្ទ "សាស្ត្រាចារ្យ/សាស្ត្រាចារ្យមហាបរិញ្ញា សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យជំនួយ" អាចអនុវត្តបានទាំងគ្រឹះស្ថានឧត្តមសិក្សានិងគ្រឹះស្ថានឧបសម្ព័ន្ធ។

ជំពូកទី២
ក្រុមប្រឹក្សាជាតិដើម្បីផ្តល់ឋានៈសាស្ត្រាចារ្យ

មាត្រា ៥.-

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិដើម្បីផ្តល់ឋានៈសាស្ត្រាចារ្យក្នុងព្រះរាជាណាចក្រកម្ពុជា សរសេរជាអក្សរកាត់ថា **ក.ជ.ស.** ដែលមានសមាសភាពដូចខាងក្រោម៖

- ឧបនាយករដ្ឋមន្ត្រី	០១រូប	ប្រធាន
- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា		អនុប្រធានអចិន្ត្រៃយ៍
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	០១រូប	អនុប្រធាន
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	០១រូប	អនុប្រធាន
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	០១រូប	អនុប្រធាន
- តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ	០២រូប	សមាជិក
- តំណាងសាស្ត្រាចារ្យក្នុងវិស័យពាក់ព័ន្ធ	០៣រូប	សមាជិក។

សមាសភាព**ក.ជ.ស.** មានអាណត្តិ៥(ប្រាំ)ឆ្នាំ ហើយអាចបន្តអាណត្តិរបស់ខ្លួនសាជាថ្មីទៀតបាន។

សមាសភាពដែលជាតំណាងសាស្ត្រាចារ្យក្នុងវិស័យពាក់ព័ន្ធ ត្រូវជ្រើសរើសនិងស្នើដោយរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធនៃវិស័យនោះ។

សមាសភាពជាក់ស្តែងនៃ**ក.ជ.ស.** ត្រូវតែងតាំងដោយអនុក្រឹត្យ។

មាត្រា ៦.-

ក.ជ.ស.មានភារកិច្ចដូចតទៅ៖

- កំណត់នីតិវិធី បែបបទស្តីពីការវាយតម្លៃការជ្រើសរើសផ្តល់ឋានៈសាស្ត្រាចារ្យ
- អនុម័តនិងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់**ក.ជ.ស.**
- អនុម័តយល់ព្រមលើសមាសភាពគណៈមេប្រយោគសម្រាប់វាយតម្លៃឋានៈសាស្ត្រាចារ្យ
- អនុម័តយល់ព្រមលើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ
- អនុម័តគម្រោងថវិកាសម្រាប់ដំណើរការ**ក.ជ.ស.**

ROYAUME DU CAMBODGE
ព្រះរាជវាំង
MINISTERE DU PALAIS ROYAL

- ទទួលនិងដោះស្រាយការប្តឹងតវ៉ារបស់គណៈមេប្រយោគឬបេក្ខជន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

មាត្រា ៧.-

គ.ជ.ស.ត្រូវប្រជុំយ៉ាងតិច១(មួយ)ដងក្នុង១(មួយ)ឆ្នាំ។

សមាជិក**គ.ជ.ស.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ការប្រព្រឹត្តទៅនៃអង្គប្រជុំនិងរបៀបរបបការងាររបស់**គ.ជ.ស.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់**គ.ជ.ស.**។

មាត្រា ៨.-

គ.ជ.ស.មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធឬទីប្រឹក្សាដើម្បីចូលរួមប្រជុំតាមការចាំបាច់។

គ.ជ.ស.អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិឬអន្តរជាតិមួយចំនួនតាមការចាំបាច់។

មាត្រា ៩.-

គ.ជ.ស.មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានទីតាំងស្ថិតនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា។

អគ្គលេខាធិការដ្ឋាននៃ**គ.ជ.ស.** ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ**គ.ជ.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ១០.-

គ.ជ.ស.មានគណៈកម្មការជំនាញតាមវិស័យនីមួយៗ ដើម្បីជួយការងារ។

គណៈកម្មការជំនាញតាមវិស័យនីមួយៗ ត្រូវបង្កើតដោយសេចក្តីសម្រេចរបស់**គ.ជ.ស.** តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ។

មាត្រា ១១.-

គ.ជ.ស.មានប្រភពធនធានមកពី៖

- ថវិកាជាតិដែលជាកញ្ចប់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា
- ថវិកាដែលបានមកពីការដាក់ពាក្យប្រឡងរបស់បេក្ខជន និង

ប្រភពផ្សេងៗទៀត។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

មាត្រា ១២.-

គ.ជ.ស.មានសិទ្ធិប្រើត្រារបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដំណើរការការងាររបស់ខ្លួន។

ជំពូកទី៣
ឋានៈសាស្ត្រាចារ្យនិងលក្ខខណ្ឌសម្រាប់ការប្រឡងជ្រើសរើស

មាត្រា ១៣.-

ឋានៈសាស្ត្រាចារ្យត្រូវបានកំណត់ដូចខាងក្រោម៖

- សាស្ត្រាចារ្យជំនួយ
- សាស្ត្រាចារ្យរង និង
- សាស្ត្រាចារ្យ/សាស្ត្រាចារ្យមហាបរិញ្ញា។

មាត្រា ១៤.-

បេក្ខជនដែលអាចប្រឡងនិងជ្រើសរើសជាសាស្ត្រាចារ្យតាមឋានៈនីមួយៗរបស់គ្រឹះស្ថានឧត្តមសិក្សា ដូចមានចែងក្នុងមាត្រា១៣ខាងលើនេះ ត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម៖

ក- សាស្ត្រាចារ្យជំនួយ

- មានសញ្ញាបត្រចាប់ពីកម្រិតក្រោយបរិញ្ញាបត្រ ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ឬសញ្ញាបត្រសមមូល ដែលទទួលស្គាល់ដោយគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សា
- មានអត្ថបទស្រាវជ្រាវដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងស្រុកឬនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិ
- បានដឹកនាំធ្វើសារណាឬនិក្ខេបបទចំពោះវិស័យសុខាភិបាល ឬបានធ្វើជាអ្នកជំនួយការដឹកនាំធ្វើនិក្ខេបបទ
- បាននិងកំពុងបង្រៀនមួយមុខវិជ្ជាដោយឯករាជ្យ និងស្រាវជ្រាវនៅគ្រឹះស្ថានឧត្តមសិក្សា ឬអង្គភាពស្រាវជ្រាវ ឬអង្គភាពនានាក្រោមឱវាទក្រសួង ស្ថាប័នពាក់ព័ន្ធ
- មិនធ្លាប់មានកំហុសវិជ្ជាជីវៈឬមិនធ្លាប់ត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារពីបទឧក្រិដ្ឋឬបទមជ្ឈិម។

ខ- សាស្ត្រាចារ្យរង

- បាននិងកំពុងបម្រើការងារជាសាស្ត្រាចារ្យជំនួយយ៉ាងតិច៤(បួន)ឆ្នាំ
- មានអត្ថបទស្រាវជ្រាវថ្មី ដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងស្រុកឬក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិ
- បានចូលរួមសន្និសីទអន្តរជាតិដោយធ្វើបទឧទ្ទេសឬធ្វើបទបង្ហាញជាផ្ទាំងរូបភាព

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL
ព្រះបរមរាជវាំង

- បានចូលរួមស្រាវជ្រាវនិងបោះពុម្ពសៀវភៅសិក្សាពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន
- មិនធ្លាប់មានកំហុសវិជ្ជាជីវៈឬមិនធ្លាប់ត្រូវបានផ្ដន្ទាទោសជាប់ពន្ធនាគារពីបទឧក្រិដ្ឋឬបទមជ្ឈិម។

គ- សាស្ត្រាចារ្យ/សាស្ត្រាចារ្យមហាបរិញ្ញា

- បាននិងកំពុងបម្រើការងារជាសាស្ត្រាចារ្យរងយ៉ាងតិច៥(ប្រាំ)ឆ្នាំ
- មានសញ្ញាបត្របណ្ឌិត
- មានអត្ថបទស្រាវជ្រាវថ្មី ដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រក្នុងស្រុកនិងក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រអន្តរជាតិ
- បានចូលរួមសន្និសីទអន្តរជាតិដោយធ្វើបទឧទ្ទេសឬធ្វើបទបង្ហាញជាផ្ទាំងរូបភាព
- បានចូលរួមស្រាវជ្រាវនិងបោះពុម្ពសៀវភៅសិក្សាពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន
- មិនធ្លាប់មានកំហុសវិជ្ជាជីវៈឬមិនធ្លាប់ត្រូវបានផ្ដន្ទាទោសជាប់ពន្ធនាគារពីបទឧក្រិដ្ឋឬបទមជ្ឈិម។

មាត្រា ១៥.-

លក្ខខណ្ឌលម្អិតពាក់ព័ន្ធនឹងជំនាញនីមួយៗសម្រាប់ការប្រឡងជ្រើសរើសសាស្ត្រាចារ្យតាមឋានៈនីមួយៗ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់**គ.ជ.ស.**។

ជំពូកទី៤
នីតិវិធីនៃការជ្រើសរើសនិងផ្ដល់ឋានៈសាស្ត្រាចារ្យ
ផ្នែកទី១
ការរៀបចំគណៈមេប្រយោគ

មាត្រា ១៦.-

គ.ជ.ស.ត្រូវរៀបចំគណៈមេប្រយោគដែលមានសមាសភាពមកពីគ្រឹះស្ថានឧត្ដមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្ដមសិក្សានៃបណ្ដាក្រសួង ស្ថាប័ននានាពាក់ព័ន្ធទៅនឹងជំនាញឯកទេស ដើម្បីរៀបចំការប្រឡងជ្រើសរើសសាស្ត្រាចារ្យ១(មួយ)ឆ្នាំម្ដង។ សមាសភាពនិងភារកិច្ចរបស់គណៈមេប្រយោគនេះ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់**គ.ជ.ស.**។

មាត្រា ១៧.-

គណៈមេប្រយោគដែលទទួលបានការតែងតាំង មានឆន្ទានុសិទ្ធិក្នុងការវាយតម្លៃលើបេក្ខជនដើម្បីទទួលបានឋានៈសាស្ត្រាចារ្យណាមួយ។/.

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ផ្នែកទី២
ការប្រឡងជ្រើសរើសនិងការផ្តល់ឋានៈ

មាត្រា ១៨.-

ចំនួនសាស្ត្រាចារ្យតាមឋានៈនីមួយៗរបស់គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់**គ.ជ.ស.**។

មាត្រា ១៩.-

បេក្ខជនដែលមានបំណងប្រឡង ដើម្បីទទួលឋានៈសាស្ត្រាចារ្យ ដូចមានចែងក្នុងមាត្រា១៣ នៃព្រះរាជក្រឹត្យនេះ ត្រូវដាក់ពាក្យស្នើសុំទៅ**គ.ជ.ស.** តាមរយៈគ្រឹះស្ថានឧត្តមសិក្សា។

ពាក្យស្នើសុំសម្រាប់ការប្រឡងជ្រើសរើស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់**គ.ជ.ស.**។

មាត្រា ២០.-

បែបបទសម្រាប់ការប្រឡងជ្រើសរើសផ្តល់ឋានៈសាស្ត្រាចារ្យ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់**គ.ជ.ស.**។

មាត្រា ២១.-

គណៈមេប្រយោគត្រូវបញ្ជូនលទ្ធផលនៃការវាយតម្លៃទៅ**គ.ជ.ស.** ដើម្បីសុំការយល់ព្រម។ រាល់ការជំទាស់ណាមួយរបស់**គ.ជ.ស.** ត្រូវមានការបញ្ជាក់ឱ្យបានច្បាស់អំពីមូលហេតុនៃការជំទាស់។

ក្នុងករណីមានវិការៈខាងទម្រង់ណាមួយក្នុងនីតិវិធីនៃការប្រឡងជ្រើសរើសដែលអាចធ្វើនិយតកម្មបាន **គ.ជ.ស.**ត្រូវធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់ ដោយតម្រូវឱ្យគណៈមេប្រយោគកែតម្រូវឡើងវិញ។

បេក្ខជនដែលមិនសុខចិត្តនឹងលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ មានសិទ្ធិប្តឹងតវ៉ាទៅ**គ.ជ.ស.** ដើម្បីស្នើសុំពិនិត្យឡើងវិញ។ ក្នុងការពិនិត្យលើការប្តឹងតវ៉ានេះ **គ.ជ.ស.**ត្រូវគោរពតាមឆន្ទានុសិទ្ធិរបស់គណៈមេប្រយោគ ដែលមានចែងក្នុងមាត្រា១៧នៃព្រះរាជក្រឹត្យនេះ។

នីតិវិធីនៃការដោះស្រាយការប្តឹងតវ៉ារបស់បេក្ខជន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ស.**។

មាត្រា ២២.-

ក្នុងករណីពុំមានការប្តឹងតវ៉ាណាមួយលើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ **គ.ជ.ស.**ត្រូវបញ្ជូនលទ្ធផលប្រឡងរបស់បេក្ខជន ជូនរាជរដ្ឋាភិបាលដើម្បីរៀបចំការតែងតាំង។

ឋានៈជាសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ/សាស្ត្រាចារ្យមហាបរិញ្ញា ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ជំពូកទី៥
អន្តរប្បញ្ញត្តិ

មាត្រា ២៣.-

ក្រោយពេលព្រះរាជក្រឹត្យនេះចូលជាធរមាន នៅពេលដែលមិនទាន់មានសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ/សាស្ត្រាចារ្យមហាបរិញ្ញាក្នុងវិស័យពាក់ព័ន្ធមួយចំនួន រាជរដ្ឋាភិបាល ត្រូវរៀបចំតែងតាំងផ្តល់ឋានៈជាសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ/សាស្ត្រាចារ្យមហាបរិញ្ញាមួយចំនួនតាមការចាំបាច់ តាមសំណើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធតាមវិស័យដោយមានការសម្របសម្រួលពីក្រសួងអប់រំ យុវជន និងកីឡា ដោយពិចារណាលើលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១៤នៃព្រះរាជក្រឹត្យនេះ។

មាត្រា ២៤.-

អនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល និងអនុក្រឹត្យលេខ២៧៤ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម នៅមានសុពលភាពអនុវត្តរហូតដល់គណៈកម្មការជំនាញក្នុងវិស័យជំនាញទាំងពីរនេះត្រូវបានបង្កើតឡើង ស្របតាមមាត្រា១០នៃព្រះរាជក្រឹត្យនេះ។

មាត្រា ២៥.-

សាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ/សាស្ត្រាចារ្យមហាបរិញ្ញា ដែលទទួលបានការតែងតាំងផ្តល់ឋានៈស្របតាមអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល និងអនុក្រឹត្យលេខ២៧៤ អនក្រ.បក ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម នៅរក្សាឋានៈដដែល។

សាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ/សាស្ត្រាចារ្យមហាបរិញ្ញាក្នុងវិស័យកសិកម្មនិងវិស័យសុខាភិបាល ដែលទទួលបានការតែងតាំងកន្លងមក ហើយមានបំណងស្នើសុំការតែងតាំងសាជាថ្មីដោយព្រះរាជក្រឹត្យ ត្រូវបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងព្រះរាជក្រឹត្យនេះ។

មាត្រា ២៦.-

ព្រះរាជក្រឹត្យនេះ មិនមានវិសាលភាពគ្របដណ្តប់លើវិស័យការពារជាតិ សន្តិសុខ និងសាសនា។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា ២៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ២៨.-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.១៣០១.០៩៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ ព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ: ៩១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៣

អគ្គលេខាធិការរងទី១ទីស្តីការរដ្ឋាភិបាល

ស៊យ សុខា

ባ/ን

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/៦៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.- កាត់ផ្ទៃដីទំហំ ៣.៦៨០ ហិកតា ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/៦៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣ ។

មាត្រា ២.- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារ. ១៣០១.០៩៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៣

លេខៈ ៩០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣
អគ្គលេខា[illegible]រដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនឯកឧត្តមឧត្តមសេនីយ៍ទោ **សុខ មុនី** អត្តលេខ ៦៨១៦៦ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរស ១៣០១.០៩៥

[illegible] ប.ល
[illegible] ឆ្នាំ២០១៣
[illegible] រដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៣

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **សេខ ម៉ាន់ធី** អត្តលេខ ០៤០១៤ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៩. ១៣០១. ០៩៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣

[illegible] ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣
[illegible] រដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **ជុំ សុយ៉ាត** អត្តលេខ ០៣១៩ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារស្រាវជ្រាវជីកគុករកអដ្ឋិធាតុជនជាតិបរទេសបាត់ខ្លួននៅកម្ពុជា ឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកឧត្តមសេនីយ៍ទោ **ជុំ សុយ៉ាត** អត្តលេខ ០៣១៩ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជានៃក្រសួងមហាផ្ទៃ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ៦. ១៣០១.០៩៧

ព្រះរាជក្រឹត្យ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
លេខ១០០៣/០២១៣/ពស/សរ

សេចក្តីសម្រេច
ស្តីពី
ការចាត់តាំងក្រុមសមាជិកាព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

- *បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា*
- *បានឃើញ ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា*
- *បានឃើញ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣*
- *បានឃើញ លទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និង អនុប្រធានទី២ ព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៣ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១២*
- *បានឃើញ សេចក្តីសម្រេចរបស់ព្រឹទ្ធសភាលេខ : ០៤២/១២១២/ពស/សរ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការរៀបចំក្រុមសមាជិកាព្រឹទ្ធសភា*
- *យោងពាក្យសុំរបស់សមាជិកាព្រឹទ្ធសភា នីតិកាលទី៣*
- *យោងស្មារតីអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នាថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣*

សម្រេច

ប្រការ ១.-

ចាត់តាំងក្រុមសមាជិកាព្រឹទ្ធសភា សម្រាប់នីតិកាលទី៣ ដូចតទៅ ៖

១- លោកជំទាវ ទី បូរ៉ាស៊ី	**ប្រធាន**
២- លោកជំទាវ មាន សំអន	**អនុប្រធាន**
៣- លោកជំទាវ ពុំ ស៊ីចាន់	**លេខាធិការ**
៤- សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី	**សមាជិក**
៥- លោកជំទាវ ឡាក់ អួន	**សមាជិក**

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail oum_sarith@camnet.com.kh

៦- លោកជំទាវ ឈូក ឈឹម **សមាជិក**

៧- លោកជំទាវ កែវ ម៉ាលី **សមាជិក ។**

ប្រការ ២. -

សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី០៥ខែកុម្ភៈ ឆ្នាំ២០១៣

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ

-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

(ដើម្បីជូនជ្រាប)

-កាលប្បវត្តិ ឯកសារ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
លេខ ០០៥/០៤២០១៣/ពស/សរ

សេចក្តីសម្រេច
ស្តីពី
ការចាត់តាំងអ្នកនាំពាក្យរបស់ព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣
- បានឃើញ លទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និង អនុប្រធានទី២ ព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៣ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១២
- បានឃើញ ព្រះរាជក្រឹត្យលេខ : នស/រកត/០៣១២/២៤៤ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ត្រាស់បង្គាប់តែងតាំងអគ្គលេខាធិការ និងអគ្គលេខាធិការរងព្រឹទ្ធសភា
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នាថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣

សម្រេច

ប្រការ ១.-

ចាត់តាំងអ្នកនាំពាក្យរបស់ព្រឹទ្ធសភា នីតិកាលទី៣ ចំនួន០២ រូប ដូចខាងក្រោម ៖

១. ឯកឧត្តម ម៉ម ប៊ុនណាង **សមាជិកព្រឹទ្ធសភា**

២. ឯកឧត្តម អ៊ុំ សារិទ្ធ **អគ្គលេខាធិការព្រឹទ្ធសភា ។**

ប្រការ ២.-

សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

p

៤-ឯកឧត្តម ប៉េង ប៉ាត់	សមាជិក
៥-ឯកឧត្តម កុក សេន	សមាជិក
៦-ឯកឧត្តម ពុធ ខូច	សមាជិក

ភូមិភាគទី៦ *(ខេត្តព្រៃវែង និងខេត្តស្វាយរៀង)*

១-លោកជំទាវ មាន សំអាន	ប្រធាន
២-ឯកឧត្តម ជា សុន	អនុប្រធាន
៣-ឯកឧត្តម គឹម ណារិន	លេខាធិការ
៤-ឯកឧត្តម ម៉ែន ស៊ីផាន់	សមាជិក
៥-ឯកឧត្តម ងឹម ផន	សមាជិក
៦-ឯកឧត្តម ឈួន ឡេង	សមាជិក

ភូមិភាគទី៧ *(ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងខេត្តព្រះសីហនុ)*

១-ឯកឧត្តម គង់ សារាជ	ប្រធាន
២-ឯកឧត្តម ឡាយ អ៊ីពិសិទ្ធ	អនុប្រធាន
៣-លោកជំទាវ ឡាក់ អួន	លេខាធិការ
៤-ឯកឧត្តម សាយ ឈុំ	សមាជិក
៥-ឯកឧត្តម លី យ៉ុងផាត់	សមាជិក
៦-ឯកឧត្តម ជុង ចន់	សមាជិក
៧-ឯកឧត្តម ជុំ ខង	សមាជិក

ភូមិភាគទី៨ *(ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី)*

១-ឯកឧត្តម ម៉ី ថង	ប្រធាន
២-ឯកឧត្តម យ៉ង់ សែម	អនុប្រធាន
៣-ឯកឧត្តម វ៉ាន់ ខុច	លេខាធិការ
៤-ឯកឧត្តម ស៊ើយ កែវ	សមាជិក
៥-លោកជំទាវ កែម ម៉ាលី	សមាជិកា

ប្រការ ២. -

សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

ចម្លងជូន

-ក្រសួងមហាផ្ទៃ

-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-អគ្គលេខាធិការដ្ឋានវុឌ្ឍសភា

(ដើម្បីជូនជ្រាប)

-កាលប្បវត្តិ ឯកសារ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

លេខ ១..../៥២០៣/ពស/សរ

សេចក្តីសម្រេច
ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣
- បានឃើញ សេចក្តីសម្រេចលេខ: ០០២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ខែមករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងលិខិតលេខ: ៨៦១ លគ.គក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ របស់គណបក្សប្រជាជនកម្ពុជា
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នាថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣

សម្រេច

ប្រការ ១.-

ទទួលស្គាល់ **ឯកឧត្តម ជុំ ឌខ** ជាសមាជិកព្រឹទ្ធសភា មណ្ឌលភូមិភាគទី៧ (ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងខេត្តព្រះសីហនុ) ជំនួស **ឯកឧត្តម អ៊ុំ សារិទ្ធ** ដែលបានសុំលាលែង ។

ប្រការ ២.-

សមាជិកព្រឹទ្ធសភាថ្មី ដែលមានចែងក្នុងប្រការ ១ ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែង ។

ប្រការ ៣.-

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលភារកិច្ចបិទផ្សាយសេចក្តីសម្រេចនេះ ក្នុងព្រឹទ្ធសភា និងផ្សព្វផ្សាយជាសាធារណៈ ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣

ប្រធានព្រឹទ្ធសភា

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី

ការកាត់ដីទំហំសរុប ៩១១,៤៨ ហិកតា នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ក្នុងនោះ កាត់ចេញពីដែនជម្រកសត្វព្រៃគូលេន-ព្រហ្មទេព កាត់ចេញពីរមណីយដ្ឋានប្រាសាទព្រះវិហារ កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងធ្វើប្រទានកម្ម ជំនួសដីសម្បទានសង្គមកិច្ច (វរៈសេនាតូចលេខ ៨១៣) សម្រាប់ប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋសរុប ៥១៣ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/១១៣ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
